# **សេចក្តីថ្លែងការណ៍រួម**

សេចក្តីថ្លែងការណ៍រួមនេះធ្វើឡើងរវាង **ធនាគារ ខេប៊ី ប្រាសាក់ (KB PRASAC)** និង **ដើមបណ្តឹង** ពាក់ព័ន្ធនឹងការវិនិយោគដោយប្រយោលរបស់ IFC ជាមួយ ធនាគារ ខេប៊ី ប្រាសាក់ តាមរយៈទំនាក់ទំនងហិរញ្ញវត្ថុជាមួយ MEF (គម្រោង IFC លេខ #27827)។ បណ្តឹងនេះត្រូវបានសម្គាល់ជាករណី "Cambodia IFC MLF and MIFA Debt Fund 04"។

នៅក្នុងដំណើរការវាយតម្លៃរបស់ CAO ដើមបណ្តឹង និងអតិថិជនបន្តរបស់ IFC គឺ ធនាគារ ខេប៊ី ប្រាសាក់ បានបង្ហាញចំណាប់អារម្មណ៍ចូលរួមក្នុងដំណើរការដោះស្រាយវិវាទ ដោយមាន CAO ជាអ្នកសម្របសម្រួល ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងក្នុងពាក្យបណ្តឹង ពាក់ព័ន្ធនឹងធនាគារ ខេប៊ី ប្រាសាក់ ដោយប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមសហការ។ ភាគីទាំងពីរបានឯកភាពលើវិធានជាមូលដ្ឋាន សម្រាប់ការសម្រុះសម្រួល នៅក្នុងខែមិថុនា ឆ្នាំ២០២៥។

ជាលទ្ធផលនៃការចូលរួមដោះស្រាយវិវាទដោយស្ម័គ្រចិត្តនេះ ភាគីទាំងពីរបានឈានដល់ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ និងបានឯកភាពឱ្យ CAO តាមដានការអនុវត្តកិច្ចព្រមព្រៀងបញ្ចប់វិវាទនេះសម្រាប់រយៈពេល ១២ (ដប់ពីរ) ខែ រហូតដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៦ ជាមួយនឹងលទ្ធភាពអាចពន្យារពេលនៃការតាមដាននេះបាន។

**សម្គាល់៖** បញ្ហានានានៅក្នុងសំណុំរឿង "Cambodia IFC MLF and MIFA Debt Fund 04" ដែលពាក់ព័ន្ធនឹងអតិថិជនបន្តរបស់ IFC គឺ អិលអូអិលស៊ី (LOLC) ត្រូវបានដោះស្រាយដាច់ដោយឡែកពីគ្នា។ pco.

Official Use Only

NB ow

Scanned with CamScanner